ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋបាលជលផល

# ឯកសារបណ្តុះបណ្តាលស្តីពីសហគ្រប់គ្រងធនធានជលផល

***គម្រោងគ្រប់គ្រងធនធានទឹកចម្រុះ ទន្លេមេគង្គ ដំណាក់កាលទី៣ (M-IWRMP-III)***

*សមាសភាគទី១៖ ការគាំទ្រដល់ការគ្រប់គ្រងធនធានជលផលនៅភូមិភាគឦសាននៃប្រទេសកម្ពុជា*

***វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាបនៃរដ្ឋបាលជលផល***
***២០១៨***

៣

# សហគ្រប់គ្រងធនធានជលផល
# ឯកសារទី៣ : ការពង្រឹងគណៈកម្មការសហគមន៍នេសាទ



គម្រោងគ្រប់គ្រងធនធានទឹកចម្រុះ ទន្លេមេគង្គ ដំណាក់កាលទី៣ ( M-IWRMP-III )

សមាសភាគទី១៖ ការគាំទ្រដល់ការគ្រប់គ្រងធនធានជលផលនៅភូមិភាគឦសាននៃប្រទេសកម្ពុជា

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប នៃរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ១. ភាពជាអ្នកដឹកនាំក្នុងគណៈកម្មការសហគមន៍នេសាទ

គណៈកម្មការសហគមន៍នេសាទ គឺជាក្រុមមនុស្សដែលមានសមាជិកបោះឆ្នោតឱ្យដើម្បីដឹកនាំសហគមន៍នេសាទ។ អ្នកដឹកនាំគួរផ្តល់នូវការទូន្មាន និងលើកទឹកចិត្តដល់សមាជិក និងបំផុសសមាជិកឱ្យយល់ដឹង និងចូលរួមអនុវត្តឱ្យបានសម្រេចបាននូវទស្សនៈវិស័យ ធ្វើការជាមួយគ្នា និងបង្កើននូវប្រសិទ្ធភាពនៃការគ្រប់គ្រងធន - ធានប្រកបដោយគុណធម៌ និងសីលធម៌សង្គម។

ភារកិច្ចរបស់អ្នកដឹកនាំ គឺនាំមនុស្សមួយក្រុមឱ្យសម្រេចគោលបំណងដែលគេចង់បាន។



## ២. គោលការណ៍គ្រប់គ្រងធនធានជលផលផ្តោតលើប្រព័ន្ធអេកូឡូស៊ី

ការគ្រប់គ្រងធនធានជលផល ប្រសិនបើមិនបានគិតគូរដល់បរិស្ថាននោះទេគឺនាំឱ្យការគ្រប់គ្រងគ្មានប្រសិទ្ធភាពឡើយ។

ដូចនេះទើបយើងស្វែងរកគោលការណ៍នៃការគ្រប់គ្រងដែលមានលក្ខណៈសមស្រប ពោលគឺការគ្រប់គ្រងដោយផ្តោតលើប្រព័ន្ធអេកូឡូស៊ី។

រដ្ឋបាលជលផល បានឯកភាពចំពោះគោលការណ៍នេះ ហើយការអនុវត្តវិធីសាស្ត្រនេះ ក្នុងការគ្រប់គ្រងសហគមន៍នេសាទ គឺជាការងារមួយល្អប្រសើរ។

ការគ្រប់គ្រងដោយផ្តោតលើប្រព័ន្ធអេកូឡូស៊ីជាការគ្រប់គ្រងគិតគូរដល់ការធ្វើឱ្យមានតុល្យភាព រវាងកត្តាបរិស្ថាន សង្គម(សុខុមាលភាព) និង អភិបាលកិច្ច។



## ២. គោលការណ៍គ្រប់គ្រងធនធានជលផលតាមបែបប្រព័ន្ធអេកូឡូស៊ី (ត)

- **បរិស្ថានល្អ៖** មានពូជត្រីច្រើនប្រភេទ ផលត្រីសម្បូរ មិនធ្វើឱ្យខូចខាតជម្រកត្រី ទឹកមានគុណភាព
- **សង្គម(សុខុមាលភាព)៖** ប្រជាពលរដ្ឋមានស្តង់ដាររស់នៅល្អ (ប្រាក់ចំណូលសមរម្យ) សុវត្ថិភាពស្បៀង ទំនាក់ទំនងសង្គមមានភាពប្រសើរឡើង និងធានាសុវត្ថិភាព
- **អភិបាលកិច្ចល្អ៖** ជាការចូលរួមសិទ្ធិជាផ្លូវការ សមធម៌ យន្តការរៀបចំផែនការ និងការអនុវត្ត ការគោរព និងពង្រឹងការអនុវត្តច្បាប់។



## ៣. តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ

- រៀបចំសេចក្តីព្រាងស្តីពីលក្ខន្តិក បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ផែនការគ្រប់គ្រង នឹងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ប្រតិបត្តិស្របតាមលក្ខខណ្ឌនៅក្នុងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត
- ស្វែងរកជំនួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុពីរដ្ឋបាលជលផល ស្ថាប័នពាក់ព័ន្ធ និងអ្នកជំនួយផ្សេងៗក្នុងការអនុវត្តដំណើរការសហគមន៍នេសាទ
- តំណាងឱ្យសហគមន៍នេសាទក្នុងការសម្រុះសម្រួល និងដោះស្រាយទំនាស់ដែលកើតមាន
- បើកគណនីធនាគារ និងគ្រប់គ្រងហិរញ្ញវត្ថុសហគមន៍នេសាទ ដោយមានតម្លាភាព និងការទទួលខុសត្រូវ



## ៣. តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ (ត)

- ធ្វើការសម្រេចចិត្តលើការអភិវឌ្ឍសហគមន៍នេសាទ ដោយមានការយល់ព្រមពីសមាជិកសហគមន៍នេសាទភាគច្រើនស្របទៅតាមលក្ខន្តិកៈសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ចូលរួមពិគ្រោះយោបល់ក្នុងការធ្វើបទបញ្ញានានាដែលពាក់ព័ន្ធដល់ផលប្រយោជន៍របស់សហគមន៍នេសាទ
- រាយការណ៍ និងផ្តល់ព័ត៌មានជាបន្ទាន់នូវរាល់បទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍ដល់រដ្ឋបាលជលផលដែលនៅជិតបំផុត
- ធ្វើការអភិរក្ស និងការពារវារីជាតិនៅក្នុងកន្លែងនេសាទសហគមន៍
- អនុវត្តតួនាទីចាំបាច់ផ្សេងៗទៀត តាមការណែនាំរបស់រដ្ឋបាលជលផល
- ធ្វើការតវ៉ាចំពោះការមិនបន្តកិច្ចព្រមព្រៀងឱ្យសហគមន៍នេសាទ។



## ៤. គណៈកម្មការសហគមន៍នេសាទ និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍



គណៈកម្មការសហគមន៍នេសាទមានភារកិច្ចរៀបចំ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។ កិច្ចព្រមព្រៀងមានន័យថាទទួលស្គាល់ និងជានាសិទ្ធិរបស់សហគមន៍ចំពោះដែននេសាទដែលបានកំណត់ព្រំប្រទល់រួច។

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវបានចុះហត្ថលេខា ដោយខណ្ឌរដ្ឋបាលជលផល និងមានហត្ថលេខាជាសាក្សីរបស់មេឃុំចៅសង្កាត់។

## ៤. គណៈកម្មការសហគមន៍នេសាទ និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ (ត)

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវបញ្ជាក់ពីចំណុចសំខាន់ៗដូចខាងក្រោម៖

- ភាគីចុះកិច្ចព្រមព្រៀង
- ទំហំកន្លែងនេសាទ
- រយៈពេលគ្រប់គ្រង និងប្រើប្រាស់កន្លែងនេសាទ
- លក្ខខណ្ឌនៃការគ្រប់គ្រង និងប្រើប្រាស់កន្លែងនេសាទ។

ក្រោយពីចុះហត្ថលេខា ត្រូវប្រថាប់ត្រារបស់ខណ្ឌរដ្ឋបាលជលផល។ កិច្ចព្រមព្រៀងនេះត្រូវចម្លងជូនសហគមន៍នេសាទ ក្រុមប្រឹក្សាឃុំសង្កាត់ ខណ្ឌរដ្ឋបាលជលផល រដ្ឋបាលក្រុងស្រុក ខណ្ឌ រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។



## ៥. តួនាទីគណៈកម្មការសហគមន៍នេសាទ ក្នុងការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ជារៀងរាល់ឆ្នាំ គណៈកម្មការសហគមន៍ ដោយទ្បែកថវិកា និងឱកាសទទួលថវិកាក៏នេសាទត្រូវរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងធ្វើ ត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ។ បច្ចុប្បន្នភាព៖




- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

**នៅក្នុងការពិនិត្យឡើងវិញត្រូវពិចារណាទៅលើ៖**

- អាទិភាពនៃបញ្ហា ការគំរាមកំហែង និងគោលបំណង
- សកម្មភាពចម្បងៗដែលទាក់ទងទៅនឹងគោលបំណង

## ៦. គណៈកម្មការសហគមន៍នេសាទ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ៦.១ ការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ចំណុចសំខាន់នៅក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍មានដូចខាងក្រោម៖

- តើមានគោលដៅ និងគោលបំណងអ្វីខ្លះ ដែលចង់សម្រេចឱ្យបាន?
- តើមានសកម្មភាពចម្បងៗអ្វីខ្លះ ដើម្បីសម្រេចគោលដៅ និងគោលបំណង?
- តើសង្ឃឹមថានឹងទទួលបានលទ្ធផលអ្វីខ្លះ?
- តើត្រូវការរយៈពេលប៉ុន្មាន ក្នុងការអនុវត្តយុទ្ធ-សាស្ត្រនេះ?
- តើអ្នកណាខ្លះជាអ្នកអនុវត្តសកម្មភាព?
- តើអ្នកណាទទួលខុសត្រូវអនុវត្តសកម្មភាព?
- តើមានតម្រូវការហិរញ្ញវត្ថុប៉ុន្មាន និងមានប្រភពមកពីណា?



## ៦.២ គណៈកម្មការសហគមន៍នេសាទណែនាំសមាជិក ទៅតាមផ្នែកសំខាន់ៗនៃផែនការគ្រប់គ្រង

សហគមន៍នេសាទខ្លះមាន ខ្លះគ្មានផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ សហគមន៍ខ្លះមានផែនការក៏ដោយ ក៏ផែនការនោះត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ដែលជាឱកាសកែសម្រួល និងបន្ថែមសកម្មភាពចាំបាច់ជាក់ស្តែងឱ្យត្រូវនឹងតម្រូវការ។

ពិនិត្យមើលអំពីខ្លឹមសារលម្អិតក្នុងផែនការល្អគួរមានដោយផ្តោតលើការងារជាក់ស្តែង និងអ្វីដែលសមាជិកគណៈកម្មការត្រូវដឹង ដើម្បីងាយស្រួលដឹកនាំសមាជិកសហគមន៍នេសាទឱ្យអនុវត្តសកម្មភាពចម្បងៗនៃផែនការ គ្រប់គ្រងកន្លែងនេសាទសហគមន៍។



## ៦.២ គណៈកម្មការសហគមន៍នេសាទណែនាំសមាជិក ទៅតាមផ្នែកសំខាន់ៗនៃផែនការគ្រប់គ្រង (ត)




គណៈកម្មការ និងសមាជិកសហគមន៍នេសាទ និងតំណាងក្រុមប្រឹក្សាឃុំសង្កាត់ និងមន្ត្រីជំនាញជលផល រួមទាំងក្រុមស្ត្រី និងជនជាតិដើមភាគតិច ជួបជុំគ្នារៀបចំកិច្ចប្រជុំដើម្បីកសាង និងធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រង។ នេះជាឱកាសដ៏សំខាន់ដើម្បីប្រមូលមតិយោបល់ឱ្យបានច្រើន។

ផែនការនេះបានកំណត់នូវយុទ្ធសាស្ត្រ និងសកម្មភាពគ្រប់គ្រងធនធានជលផល ក៏ដូចជាតួនាទី និងការទទួលខុសត្រូវក្នុងចំណោមដៃគូរួមមាន៖ សមាជិកគណៈកម្មការសហគមន៍នេសាទ សមាជិកសហគមន៍នេសាទ និងស្ថាប័នជំនាញរាជរដ្ឋាភិបាល។

## ៦.២.១ ទស្សនៈវិស័យរបស់សហគមន៍នេសាទ

ក្នុងអំឡុងពេលពិគ្រោះយោបល់ជាមួយ សមាជិកសហគមន៍នេសាទ គណៈកម្មការត្រូវ សម្របសម្រួលក្រុមឱ្យបង្កើតទស្សនៈវិស័យ។ ទស្សនៈវិស័យរៀបរាប់អំពីស្ថានភាពដែលគណៈ កម្មការ និងសហគមន៍នេសាទចង់បាននាពេល អនាគត។ *ឧទា. "នៅឆ្នាំ២០៣០ ធនធានជលផលរបស់សហគមន៍យើងមាន៖*

- *ប្រព័ន្ធអេកូឡូស៊ីល្អប្រសើរ*
- *ផ្តល់នូវផលប្រយោជន៍ប្រកបដោយសមធម៌ ដល់សមាជិកសហគមន៍ និងប្រជាពលរដ្ឋតាម រយៈកិច្ចសហការរួមគ្នា និងស្របច្បាប់ ក្នុងការ គ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព"*

ឬ *"ដើម្បីធ្វើឱ្យមាននិរន្តរភាពនូវផលស្តុកនៅរយៈពេល២០ឆ្នាំទៀត សម្រាប់គ្រប់គ្រួសារ នៃសហគមន៍នេសាទ"*។



## ៦.២.២ ការកំណត់បញ្ហា និងការគំរាមកំហែង

នៅពេលពិគ្រោះយោបល់ គណៈកម្មការសហគមន៍នេសាទត្រូវបំផុសដល់សមាជិកសហគមន៍ នេសាទលើកឡើងពីបញ្ហា និងការគំរាមកំហែងដែលទាក់ទងនឹងវិស័យជលផល។

បញ្ហា និងការគំរាមកំហែងរួមមាន៖

- បញ្ហាបរិស្ថាន៖ កិច្ចការពារ និងស្តារជម្រកត្រី ការកាត់បន្ថយការបំពុលទឹក គ្រប់គ្រងកាកសំណល់ និងធនធានជលផល
- បញ្ហាសង្គម៖ សុវត្ថិភាពស្បៀង ការចិញ្ចឹមជីវិតដែលមាននិរន្តរភាព និងហេដ្ឋារចនាសម្ព័ន្ធជនបទ
- បញ្ហាអភិបាលកិច្ច៖ ការចូលរួម ការផ្តល់អំណាច និងពង្រឹងស្ថាប័នជាដើម។



### ៦.២.៣ ការចាត់អាទិភាពបញ្ហា និងការគំរាមកំហែង

បន្ទាប់ពីកំណត់បញ្ហាត្រូវចាត់អាទិភាពបញ្ហា មានន័យថាជ្រើសរើសសកម្មភាពសំខាន់ៗ រួចកំណត់សកម្មភាពដែលសំខាន់ជាងគេ និងជាបន្តបន្ទាប់ៗល។ ការងារនេះត្រូវរៀបទៅតាមលំដាប់លំដោយអាទិភាពនៃសកម្មភាពនីមួយៗ។



## ៦.២.៤ ការកំណត់តម្រូវការ និងចាត់អាទិភាព

គណៈកម្មការសហគមន៍នេសាទត្រូវសម្របសម្រួលជាមួយសមាជិក ក្នុងការកំណត់តម្រូវការ និងចាត់អាទិភាព ដែលឆ្លើយតបនឹងបញ្ហា និងការគំរាមកំហែងដែលរកឃើញខាងលើ។

**ការកំណត់តម្រូវការ និងចាត់អាទិភាពដែលទាក់ទងជាមួយបញ្ហានិងការគំរាមកំហែង៖**

- បញ្ជីតម្រូវការត្រូវរៀបចំឱ្យច្បាស់លាស់ និងមានចំនួនជាក់លាក់ ដោយផ្តោតលើតម្រូវការណាដែលគណៈកម្មការនិងសហគមន៍នេសាទត្រូវដោះស្រាយ
- ត្រូវរកតម្រូវការសំខាន់ដែលចាំបាច់ ចម្បងបន្ទាន់ជាងគេ និងជ្រើសរើសជាបន្តបន្ទាប់តាមលំដាប់លំដោយ ដើម្បីឱ្យសហគមន៍នេសាទឆ្លើយតបនឹងតម្រូវការ និងដែលទទួលបានលទ្ធផលល្អ។



## ៦.២.៥ ការកំណត់គោលដៅ និងគោលបំណង

គោលដៅ និងគោលបំណងត្រូវមានទំនាក់ទំនងជាមួយនឹងបញ្ហា និងការគំរាមកំហែង។ គោលដៅបែកចេញជា៖ ១)គោលដៅផ្នែកបរិស្ថាន ២)គោលដៅផ្នែកសង្គម និង៣)គោលដៅផ្នែកអភិបាលកិច្ច។ គោលបំណងត្រូវរៀបចំឡើងស្របតាមគោលដៅ និងឆ្លើយតបនឹងបញ្ហានានា។



## ៦.២.៦ ការកំណត់វិធានការគ្រប់គ្រង

គណៈកម្មការសហគមន៍នេសាទត្រូវជួយសមាជិកកំណត់វិធានការគ្រប់គ្រង សម្រាប់គោលបំណងនីមួយៗ។ វិធានការគ្រប់គ្រង គឺជាសកម្មភាពនានា ដើម្បីសម្រេចគោលបំណង។

- លទ្ធផលរំពឹងទុក (បង្កើតអ្វី ឬមានអ្វីដែលផ្លាស់ប្តូរ)
- ពេលវេលា (តើយុទ្ធសាស្រ្ត ត្រូវបានអនុវត្តក្នុងអំឡុងពេលណា?)
- អ្នកអនុវត្តសកម្មភាព (តម្រូវការ កិច្ចសហប្រតិបត្តិការក្នុងការអនុវត្តសកម្មភាព)
- អ្នកទទួលខុសត្រូវឬស្ថាប័នអនុវត្តសកម្មភាព (អ្នកទទួលខុសត្រូវ ចំពោះការអនុវត្ត)
- តម្រូវការ និងប្រភពហិរញ្ញវត្ថុ។



# ៦.២.៦ ការកំណត់វិធានការគ្រប់គ្រង (ត)

| គោលបំណង | សូចនាករ | វិធានការ |
|---|---|---|
| កាត់បន្ថយ មូលហេតុត្រីងាប់ ឧទា. អាងស្តុកទឹក | បន្ថយកន្លែងស្ទាក់ទឹកចំនួន ២០% ក្នុងពេល ៣ឆ្នាំ | នៅឆ្នាំទី១ កំណត់ កន្លែងស្ទាក់ទឹក ដែលបង្កផលប៉ះពាល់ និងរកដម្រើសរំលាយចោល |
| អភិរក្សកន្លែងត្រីពងកូន | ហាមឃាត់ការធ្វើនេសាទនៅកន្លែងចំនួន ២ ដែលត្រីធ្លាប់ពងកូន | កំណត់តំបន់គោលដៅចំនួន២ នៅរដូវ បិទនេសាទ និងបង្កើតក្រុមល្បាត១ |
| ធ្វើឱ្យត្រីមានទំហំធំ | កាត់បន្ថយ មងក្រឡាញឹក ៣០% ក្នុងពេល៣ឆ្នាំ | កំណត់បានទំហំក្រឡាមងដែលហាមឃាត់ និងរកវិធីពង្រឹងការអនុវត្តច្បាប់ |
| ធ្វើឱ្យប្រសើរឡើងការលក់ដូរផលនេសាទ | ឆ្នាំក្រោយ សហគមន៍នេសាទទិញបានម៉ូតូ១ ដឹកត្រីលក់នៅផ្សារ | ប្រមូលថវិកាទិញម៉ូតូ១គ្រឿង |
| កាត់បន្ថយសមត្ថភាពនេសាទ | អ្នកនេសាទស្ម័គ្រចិត្ត ៥នាក់ ក្លាយកសិករ ១០០% ក្នុងពេល ៥ឆ្នាំក្រោយទទួលបានដី | កំណត់ទីតាំងដីទុកឱ្យអ្នកស្ម័គ្រចិត្ត ធ្វើរបរកសិកម្ម និងឈប់នេសាទ |
| បង្កើនផលប្រយោជន៍អ្នកនេសាទ | ទិញទូរស័ព្ទ១ទុក ដើម្បីដឹងពីតម្លៃផលនេសាទពីអ្នកលក់ត្រី ៣នាក់ យ៉ាងតិច | ប្រមូលថវិកាទិញទូរសព្ទ១ និងកំណត់ អ្នកទទួលបន្ទុកស្ទង់តម្លៃត្រីប្រចាំថ្ងៃ |
| បង្កើនផលប្រយោជន៍ស្ត្រី | ប្រមូលថវិកាធ្វើរោងឆ្អើត្រីនៅឆ្នាំទី២ | កំណត់ទីតាំង និងតម្លៃ សង់រោងឆ្អើរត្រី និងចងក្រងក្រុម រួចបង់ថវិកា |

## ៦.៣ បញ្ហាយេនឌ័រ និងជនជាតិដើមភាគតិច ក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គណៈកម្មការសហគមន៍នេសាទត្រូវគិតគូរ អំពីសកម្មភាពយេនឌ័រ ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះ ដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

កិច្ចប្រជុំក្រុមស្ត្រីគួរត្រូវរៀបចំដោយឡែក ដើម្បីកំណត់បញ្ហាតម្រូវការ និងឱកាសរបស់ស្ត្រី និងបញ្ចូលបញ្ហា តម្រូវការ និងឱកាសទាំងនោះ ទៅក្នុងផែនការគ្រប់គ្រង។ គណៈកម្មការសហគមន៍នេសាទត្រូវពិនិត្យមើល៖

- គោលដៅ និងគោលបំណង ឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី និងជនជាតិដើមភាគតិច
- សកម្មភាពនានា ដែលលើកកម្ពស់ការចូលរួមរបស់ស្ត្រី និងជនជាតិដើមភាគតិចក្នុងសហគមន៍ និងគណៈកម្មការសហគមន៍
- លទ្ធផលត្រូវសម្រេចឱ្យបានតាមករណីនីមួយៗ
- ការវិនិយោគដើម្បីសម្រេចគោលបំណង
- អ្នកទទួលខុសត្រូវ/ ក្រុមតាមដានលទ្ធផល។



## ៧. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រង

ការគ្រប់គ្រងសហគមន៍នេសាទ គឺជាដំណើរការជាបន្តបន្ទាប់ ដើម្បីសម្រេចគោលបំណងដែលបានគ្រោងទុក។

- ការតាមដានត្រួតពិនិត្យ ថាតើផែនការត្រូវបានអនុវត្តតាមការគ្រោងទុកដែរឬទេ ?
- ការវាយតម្លៃ ថាតើអ្វីជាជោគជ័យ និងបរាជ័យព្រមទាំងការរៀនសូត្រពីបទពិសោធន៍ដូចម្ដេច ?
- ការវាយតម្លៃរួមមានការពិនិត្យមើលលទ្ធផលដែលបានអនុវត្ត និងវាយតម្លៃថាតើសកម្មភាពទាំងនោះទទួលបានផ្លែផ្កា។

កិច្ចការនេះជួយឱ្យមានភាពបត់បែន និងធ្វើឱ្យប្រសើរឡើងតាមរយៈការរៀនសូត្រ និងបទពិសោធន៍។



## ៨. គណៈកម្មការសហគមន៍នេសាទ និងការគ្រប់គ្រងវិវាទ

នៅក្នុងអាណត្តិ៥ឆ្នាំរបស់ខ្លួន គណៈកម្មការសហគមន៍នេសាទអាចជួបនឹងវិវាទមួយចំនួន រវាងសមាជិកសហគមន៍ និងប្រជាពលរដ្ឋ និងរវាងសហគមន៍នេសាទ និងអ្នកខាងក្រៅ។

គណៈកម្មការសហគមន៍នេសាទត្រូវទទួលស្គាល់ថា ភាគីវិវាទមានទស្សនៈផ្ទុយគ្នាអំពីដំណោះស្រាយជាក់លាក់ ហើយទស្សនៈរបស់ភាគីនីមួយៗតែងមានហេតុផលរៀងៗខ្លួន។

គោលដៅនៃការគ្រប់គ្រងមិនមែនមានន័យថា គេចវេសពីវិវាទនោះទេ ប៉ុន្តែភាគីទាំងអស់រួមគ្នាដោះស្រាយ។

**ការគ្រប់គ្រងវិវាទរួមមាន៖**

- **ការចរចា៖** ភាគីជួបគ្នាទល់មុខ ដោយមាន ឬគ្មានអ្នកសម្របសម្រួល ឈានដល់ឯកភាពលើដំណោះស្រាយសមស្របមួយចំនួន
- **ការសម្រុះសម្រួល៖** អ្នកសម្រុះសម្រួល (ភាគីទី៣អព្យាក្រិត) ជួយភាគីក្នុងវិវាទឈានដល់ការចរចា តែគាត់មិនមានអំណាចបង្ខំភាគីទាំងពីរឱ្យយកដំណោះស្រាយណាមួយទេ
- **ការផ្សះផ្សា៖** អ្នកសម្រុះសម្រួលអព្យាក្រិតជួបភាគីដោយឡែកពីគ្នា ដើម្បីបន្ថយកំហឹង និងឯកភាពចំពោះដំណើរការដោះស្រាយ
- **អាជ្ញាកណ្តាល៖** ជួបជាមួយភាគីវិវាទ និងមានសិទ្ធិឱ្យភាគីទទួលយកដំណោះស្រាយ។



# ៨. គណៈកម្មការសហគមន៍នេសាទ និងការគ្រប់គ្រងវិវាទ (ត)

យន្តការដោះស្រាយវិវាទរួមមាន៖

ការដោះស្រាយវិវាទដំបូងៗ (ពេលដែលភាគីទាំងអស់ត្រៀមខ្លួននឹងដោះស្រាយ)

- អ្នកណាជាអ្នកជួយដោះស្រាយ
- អ្នកណាជាអ្នកសម្រេច ក្នុងករណីដែលមិនមានការឯកភាពគ្នា។

វិវាទធំៗ (ពេលដែល ភាគីទាំងអស់ទំនងជាមិនឯកភាពគ្នា)

- អ្នកណាជាអ្នកជួយដោះស្រាយ
- អ្នកណាជាអ្នកសម្រេច ក្នុងករណីដែលមិនមានការឯកភាពគ្នា។



## ៩. តួនាទីគណៈកម្មការសហគមន៍នេសាទចំពោះការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់

ការពង្រឹងការអនុវត្តច្បាប់មាន វិធីសាស្ត្រជាច្រើនដើម្បីផ្លាស់ប្តូរផ្នត់គំនិតជនល្មើស។ អន្តរាគមន៍ពង្រឹងការអនុវត្តច្បាប់ ជាវិធានការបង្ការទន់ភ្លន់ ឬផាកពិន័យ។

**វិធានការទន់ភ្លន់ ជំរុញការអនុវត្តច្បាប់ដោយស្ម័គ្រចិត្ត។ វិធីសាស្ត្ររួមមាន៖**

- រៀបចំទិវាសំខាន់ៗ កិច្ចប្រជុំសាធារណៈ ទស្សនកិច្ចសិក្សា ការចែករំលែកបទពិសោធន៍ជំរុញការអនុវត្តល្អៗ និងកម្មវិធីតាមសាលា។

**វិធានការក្តៅ រួមមាន៖**

- បង្ក្រាប និងផាកពិន័យ ជាដំណើរការបន្តបន្ទាប់នៃការល្បាត និងការចាប់ជនល្មើស។

ក្រៅពីវិធានការក្តៅ គណៈកម្មការសហគមន៍នេសាទគួរពិចារណាអំពីវិធានការទន់ភ្លន់ ហើយក៏ត្រូវកំណត់អ្នកទទួលខុសត្រូវក្នុងការពង្រឹងការអនុវត្តច្បាប់។



## ១០. តួនាទីនៃគណៈកម្មការសហគមន៍នេសាទក្នុងការកៀរគរថវិកា

គណៈកម្មការសហគមន៍នេសាទត្រូវការធនធានហិរញ្ញវត្ថុ។ ផែនការថវិកាត្រូវរៀបចំឡើងដោយឈរលើមូលដ្ឋាននៃការវាយតម្លៃរាល់ការចំណាយចំពោះសកម្មភាពនានា។ សហគមន៍នេសាទត្រូវកំណត់៖

- ការចំណាយលើសកម្មភាពសំខាន់ៗ ដូចជា៖ ចំណាយទៅលើហេដ្ឋារចនាសម្ព័ន្ធ ឧបករណ៍សម្ភារ (ទូកល្បាត ឧបករណ៍ត្រួតពិនិត្យ និងទំនាក់ទំនង) និងចំណាយប្រតិបត្តិការរួមមានប្រេង អាហារ និងចំណាយលើកិច្ចប្រជុំជាដើម។
- ប្រភពហិរញ្ញវត្ថុដូចជា៖ ជំនួយរបស់រាជរដ្ឋាភិបាល អំណោយ និងជំនួយ ចំណូលពីទេសចរណ៍ ចំណូលពីសិប្បកម្ម និងចំណូលក្រុមសន្សំ
- ពេលវេលាគ្រោងទុកនៃការចំណាយ និងចំណូល ដើម្បីងាយស្រួលក្នុងការព្យាករណ៍ចរន្តថវិកាឱ្យទាន់ពេលវេលា។



# ១០. តួនាទីនៃគណៈកម្មការសហគមន៍នេសាទក្នុងការកៀរគរថវិកា (ត)

ប្រភពធនធានហិរញ្ញវត្ថុរួមមាន៖

- ចំណូលពីទេសចរណ៍ (សំបុត្រចូលទស្សនា និងជិះទូកកំសាន្ត ថ្លៃស្នូចត្រីលំហែ... )
- ជំនួយ និងអំណោយ (ភ្នាក់ងារផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន..)
- ចំណូលពីសិប្បកម្ម (របស់របរធ្វើដោយដៃ ផលិតផល វត្ថុអនុស្សាវរីយ៍)
- ចំណូលពីក្រុមសន្សំប្រាក់ ឥណទានខ្នាតតូច
- ជំនួយពីរាជរដ្ឋាភិបាលនិងប្រភពផ្សេងទៀត.។



## ១១. តួនាទីគណៈកម្មការសហគមន៍នេសាទក្នុងការរៀបចំផែនការសកម្មភាព និងរបាយការណ៍
### ១១.១ ការរៀបចំផែនការសកម្មភាព

ដោយឈរលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ផែនការសកម្មភាពគឺជាការកំណត់នូវសកម្មភាព តម្រូវការ និងបញ្ហាសំខាន់ៗ ដែលត្រូវដោះស្រាយក្នុងរយៈពេល៣ខែ។ ផែនការបញ្ជាក់នូវសកម្មភាព គោលបំណង តម្រូវការសម្ភារ អ្នកទទួលខុសត្រូវអនុវត្ត ថវិកា ទីកន្លែង និងពេលវេលា។



គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំផែនការសកម្មភាព និងពិនិត្យឡើងវិញជារៀងរាល់ខែ នៅពេលមានកិច្ចប្រជុំ។ ផែនការសកម្មភាពត្រូវត្រួតពិនិត្យរៀងរាល់៣ខែម្តង ទន្ទឹមនឹងផែនការថ្មីបានរៀបចំឡើង។

## ១១. តួនាទីគណៈកម្មការសហគមន៍នេសាទក្នុងការរៀបចំផែនការសកម្មភាព និងរបាយការណ៍ (ត)
## ១១.២ ការធ្វើរបាយការណ៍

គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំរបាយកាណ៍រៀងរាល់ ៣ ខែម្តង ជូនខណ្ឌរដ្ឋ-បាលជលផលតាមរយៈផ្នែករដ្ឋបាលជលផល និងចម្លងជូនក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវរក្សាទុកនៅគណៈកម្មការសហគមន៍នេសាទ។

គម្រូរបាយការណ៍របស់សហគមន៍នេសាទត្រូវកំណត់ដោយរដ្ឋបាលជលផលដែលរៀបរាប់ពីចំណុចសំខាន់ៗជាអាទិ៍ដូចខាងក្រោម៖

- លទ្ធផលនៃការអនុវត្តកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- លទ្ធផលនៃការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សកម្មភាពរីកចំរើនរបស់សហគមន៍នេសាទ
- សង្ខេបអំពីស្ថានភាពចំណូល និងការចំណាយថវិការបស់គណៈកម្មការសហគមន៍នេសាទ
- បញ្ហាដែលបានជួបប្រទះព្រមទាំងអនុសាសន៍សម្រាប់កែលម្អ
- ទិសដៅ និងសកម្មភាពការងារសម្រាប់អនុវត្តក្នុងខែ ត្រីមាស ឆមាស និងឆ្នាំបន្ទាប់។



## ១២. កិច្ចសហការជាមួយខណ្ឌរដ្ឋបាលជលផល

គណៈកម្មការសហគមន៍នេសាទធ្វើការជាមួយខណ្ឌរដ្ឋបាលជលផលលើកិច្ចការមួយចំនួនដូចជា៖ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ការពង្រឹង ការអនុវត្តច្បាប់ និងរបាយការណ៍។

គណៈកម្មការសហគមន៍នេសាទត្រូវស្គាល់អ្នកទទួលបន្ទុករបស់ខណ្ឌរដ្ឋបាលជលផល និងអញ្ជើញពួកគាត់ឱ្យចូលរួមកិច្ចប្រជុំ និងសកម្មភាពផ្សេងៗរបស់សហគមន៍ ដើម្បីឱ្យពួកគាត់ដឹងអំពីសហគមន៍នេសាទ។ ការប្រាស្រ័យទាក់ទងដែលមានលក្ខណៈបើកចំហ គឺជានាំនូវភាពជោគជ័យរបស់សហគមន៍នេសាទ។

ខណ្ឌរដ្ឋបាលជលផលមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- យល់ព្រម និងឯកភាពលើកិច្ចព្រមព្រៀង
- សង្កេតការណ៍ដំណើរការបោះឆ្នោតគណៈកម្មការសហគមន៍នេសាទ
- យល់ព្រមលើបច្ចុប្បន្នភាពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ប្រថាប់ត្រាលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍



## ១២. កិច្ចសហការជាមួយខណ្ឌរដ្ឋបាលជលផល (ត)

- ពិនិត្យ និងយល់ព្រមលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ពិគ្រោះយោបល់អំពីការកំណត់ព្រំប្រទល់ និងផែនទីសហគមន៍នេសាទ
- ពិនិត្យរបាយការណ៍ប្រចាំត្រីមាស និងរបាយ-ការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍
- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស ដាក់ជូនរដ្ឋបាលជលផល
- ផ្តល់ជំនួយបច្ចេកទេស និងប្រឹក្សាយោបល់ដល់សហគមន៍នេសាទ ដូចជាការផ្សព្វផ្សាយបំផុស និងការផ្តល់អំណាចជាដើម
- បង្កើត និងកែសម្រួលគោលនយោបាយ និងផែនការអភិវឌ្ឍន៍ដែលទាក់ទងនឹងសហគមន៍នេសាទ
- បង្កើតផែនការសកម្មភាពគ្រប់គ្រង
- សម្របសម្រួលការអនុវត្តផែនការជាមួយសហគមន៍នេសាទ
- តាមដានត្រួតពិនិត្យសកម្មភាពសហគមន៍នេសាទ
- ពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត
- ជួយសម្របសម្រួលវិវាទ
- វាយតម្លៃលទ្ធផលនៃការអនុវត្តផែនការ។



# ១៣. បញ្ចូលលទ្ធផលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

លទ្ធផលផែនការគ្រប់គ្រងត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដើម្បីឱ្យឃុំ សង្កាត់ កៀរគរធនធានទាំងក្នុង និងក្រៅមូលដ្ឋាន និងសម្រេចអំពីការប្រើប្រាស់ធនធាននោះក្នុងការដោះស្រាយបញ្ហា និងបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋមូលដ្ឋាន។

គណៈកម្មការសហគមន៍នេសាទមានវិធីច្រើនក្នុងការចូលរួម៖

- អញ្ជើញក្រុមប្រឹក្សាឃុំ សង្កាត់ចូលរួមក្នុងដំណើរការកសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- គណៈកម្មការសហគមន៍ចូលរួមក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- សម្របសម្រួលសហប្រតិបត្តិការរវាងក្រុមប្រឹក្សាឃុំ និងសមាជិកសហគមន៍នេសាទ

នៅមុនកិច្ចប្រជុំសមាហរណកម្មនៅថ្នាក់ក្រុងស្រុកខណ្ឌ សហគមន៍ត្រូវរៀបចំឯកសារ និងសម្ភារមួយចំនួនដើម្បីជានាកិច្ចពិភាក្សាឱ្យភាពរលូន និងបានលទ្ធផលរំពឹងទុកដូចជា៖ កម្មវិធីវិនិយោគបីឆ្នាំរំកិល (ដោយមានកិច្ចព្រមព្រៀងនៅក្នុងសមាហរណកម្មនៅថ្នាក់ក្រុងស្រុក ខណ្ឌ) ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

